**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខ :..........២៣៨..........ក.ប/ប្រ.ក

# ប្រកាស
## ស្តីពី
## ការកំណត់បញ្ជីជំងឺរ៉ាំរ៉ៃនៅក្នុងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- បានឃើញអនុក្រឹត្យលេខ ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទៈ(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៦ ស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- បានឃើញប្រកាសលេខ ១០៩ ក.ប/ប្រ.ក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦ ស្តីពីតារាងកាលិកថែទាំសុខភាព
- យោងស្មារតីកិច្ចប្រជុំក្រុមប្រឹក្សាភិបាលនៃបេឡាជាតិរបបសន្តិសុខសង្គម លើកទី៣៣ អាណត្តិទី៣ ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៦

## សម្រេច

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងកំណត់បញ្ជីជំងឺរ៉ាំរ៉ៃនៅក្នុងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

**ប្រការ ២.-**

ប្រភេទជំងឺរ៉ាំរ៉ៃ ដែលត្រូវកំណត់ក្នុងប្រកាសនេះមានដូចខាងក្រោម៖

១. ជំងឺខ្សោយបេះដូង (Cardiac Failure)

២. ជំងឺសាច់ដុំបេះដូង (Cardiomyopathy)

៣. ជំងឺរលាកថ្លើមប្រភេទបេរ៉ាំរ៉ៃ (Chronic Hepatitis B)

៤. ជំងឺរលាកថ្លើមប្រភេទសេរ៉ាំរ៉ៃ (Chronic Hepatitis C)

៥. ជំងឺតំរងនោមរ៉ាំរ៉ៃ (Chronic renal disease)

៦. ជំងឺក្រិនថ្លើម (Cirrhosis of the liver)

៧. ជំងឺសរសៃឈាមក្រហមបេះដូង (Coronary Artery Disease)

៨. ជំងឺទឹកនោមផ្អែមប្រភេទទី១ និងទី២ (Diabetes Mellitus Type 1 & 2)

៩. ជំងឺវិបត្តិចង្វាក់បេះដូង (Dysrhythmias)

១០. ជំងឺក្រិនសរីរាង្គ (Multiple Sclerosis)

១១. ជំងឺវិកលចរិត (Schizophrenia)

១២. ជំងឺលុយពុស (Systemic Lupus Erythematosus)

១៣. ជំងឺលើសឈាម (Hypertension)

១៤. ជំងឺតាឡាសសីមី (Thalassemia)

**ប្រការ ៣.-**

បេឡាជាតិរបបសន្តិសុខសង្គម ត្រូវទទួលបន្ទុកផ្តល់សេវាជំងឺរ៉ាំរ៉ៃដូចមានចែងក្នុងប្រការ ២ នៃប្រកាសនេះ តាមការកំណត់ក្នុងប្រការ ៥ នៃប្រកាសលេខ ១០៩ កប/ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦ ស្តីពីតាវកាលិកថែទាំសុខភាព។

**ប្រការ ៤.-**

ការកែសម្រួលបញ្ជីជំងឺរ៉ាំរ៉ៃដូចមានចែងក្នុងប្រការ២ នៃប្រកាសនេះ នឹងត្រូវកំណត់ដោយប្រកាសរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**ប្រការ ៥.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ ៦.-**

បេឡាជាតិរបបសន្តិសុខសង្គម កម្មករនិយោជិត និយោជក និងមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

__កន្លែងទទួល:__

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- បេឡាជាតិរបបសន្តិសុខសង្គម "ដើម្បីអនុវត្ត"
- សាលារាជធានី ខេត្ត
- កាលប្បវត្តិ-ឯកសារ